ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

# នាមនាមប្រជារាស្ត្រខ្មែរ

លេខ : ៣៨

## តុលាការកំពូល

ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៥

សាលដីកា

លេខ : ៩២

ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៥

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | ឃឹម ប៉ុណ្ណ | ប្រធាន |
| ២- | លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- | លោក | វឿល មួន | ចៅក្រម |
| ៤- | លោក | សោម ស៊ីវឌ្ឍ | ចៅក្រម |
| ៥- | លោក | យស់ សូខឿន | ចៅក្រម-របាយការណ៍ |

ក្រឡាបញ្ជី

លោក ជុន លៀង

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ៨៦ "ជ" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៣៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

***ចំពោះ*** : ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ តាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់នៃទោសបទឧក្រិដ្ឋ ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២ ។

-ជនជាប់ចោទឈ្មោះកែវ ហុងលីម (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ កើតនៅក្រុងភ្នំពេញ ទីលំនៅផ្ទះលេខ២១ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ មុខរបរសិស្ស ។ ឪពុកឈ្មោះកែវ ស៊ាហុង "រ" ម្តាយឈ្មោះតឹម វឿន "រ" ។ ទោសពីមុនគ្មាន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះចុង ជានិត ភេទប្រុស អាយុ១៨ឆ្នាំ ទីលំនៅផ្ទះលេខ៥ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

-អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ "ជាម្ចាស់បណ្តឹងសាទុក្ខ" ។

-តាមរបាយការណ៍សំយោគ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ នគរបាលខ័ណ្ឌដូនពេញបានបញ្ជាក់ថា : នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២ វេលាម៉ោង០៦$^{H}$៣០នាទីព្រឹក ជនរងគ្រោះចេញពីផ្ទះមករៀនគួរ

នៅក្នុងអនុវិទ្យាល័យវត្តភ្នំ ពេលទៅដល់សាលា គឺពុំទាន់មានសិស្សមកច្រើនទេ ។ នៅខណៈពេលដែលជនរងគ្រោះកំពុងអង្គុយលេងនៅមុខថ្នាក់រៀន ស្រាប់តែជនល្មើសឈ្មោះកែវ ហុងលីម និង បក្សពួក០៣នាក់ទៀត បានចូលមកក្រឞួចអាវជនរងគ្រោះរួចវាយជាច្រើនដៃ ហើយដោះយកសំភារៈពីជនរងគ្រោះរួមមានជញ្ជៀនប្លាទីនមួយវង់ តំលៃ៣០ដុល្លា ប្រាក់ដុល្លាអាមេរិក ចំនួន១៥ដុល្លា នាឡិកាដៃមួយគ្រឿង និង ស្បែកជើងមួយគូ បន្ទាប់មកក្រុមជនល្មើសបានរត់គេចខ្លួនបាត់ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញ ថា : សំរេចចោទប្រកាន់ឈ្មោះកែវ ហុងលីម ភេទប្រុសអាយុ១៧ឆ្នាំ ជាតិខ្មែរ (នៅលីវ) មានទីលំនៅបច្ចុប្បន្នផ្ទះលេខ២១ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ពីបទ : ប្លន់យកទ្រព្យសម្បត្តិអ្នកដទៃ តាមដីកាលេខ ៣០៧៣/២០០២ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៩"ខ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-លើកលែងចោទប្រកាន់អោយឈ្មោះកែវ ហុងលីម ភេទប្រុស អាយុ១៧ឆ្នាំ រួចខ្លួនពីបទចោទ ប្លន់កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០២ ប្រព្រឹត្តនៅទីក្រុងភ្នំពេញ ចាប់ពីពេលនេះតទៅ ។

២-ផ្តន្ទាទោសលើឈ្មោះកែវ ហុងលីម ភេទប្រុស អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ។ ពីបទប្លន់តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោស នៃបទឧក្រិដ្ឋ និង មាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៣ របស់លោកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ០៩"ខ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា :

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៣ របស់អយ្យការ អមតុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-បដិសេធសាលក្រមលេខ០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-ជំនុំជំរះឡើងវិញអោយបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ដែលបានចោទប្រកាន់ ដោយអយ្យការក្រុងភ្នំពេញ ទាំងបទល្មើសប្លន់កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២ ផង និង ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០២ ផង ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤៦"ជ" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០៩"ខ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការវៀរលែងតែចំណុចទី១ នៃសាលក្រមត្រូវបដិសេធចោលដោយសំរេចផ្ដន្ទាទោសលើឈ្មោះកែវ ហុងលីម ភេទប្រុស អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់០១ឆ្នាំ តែទោសនេះព្យួរទាំងអស់ ដោយទុករយៈពេលសាកល្បងប្រាំឆ្នាំ(៥ឆ្នាំ) ។ បទល្មើសដែលមានចែង និង ផ្ដន្ទាទោសតាមមាត្រា៤៥ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ មេធាវីជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ១១០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៣របស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៤៦"ជ" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចកែប្រែបទល្មើសខុសពីប្រភេទអំពើល្មើស ដែលជាអំពើប្លន់ . ផ្ដល់ស្ថានសំរាល និង ព្យួរទោស ខុសពីច្បាប់ទំងន់ទោស ។

-បានឃើញសារណា ក្នុងបណ្ដឹងសាទុក្ខលេខ៤១០ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ របស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ( ជាម្ចាស់បណ្ដឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះកែវ ហុងលីម ( ជាចុងបណ្ដឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្ដាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

+មានបន្ទុក និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះកែវ ហុងលីម ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០២ នៅក្រុងភ្នំពេញ ។

+បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៤៦"ជ" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

-បានស្ដាប់ក្រឡាបញ្ជីអានបណ្ដឹងសាទុក្ខ និង សារណារបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍នៅពេលជំនុំជំរះ ។

-បានស្ដាប់ចម្លើយអះអាងរបស់ឈ្មោះកែវ ហុងលីម ( ជាចុងបណ្ដឹងសាទុក្ខ) នៅពេលជំនុំជំរះថា: ខ្ញុំមិនបានវាយគេទេ ព្រឹកឡើងខ្ញុំបាទបានទៅសាលារៀន ឃើញឈ្មោះចុង ជានិត អង្គុយមុខថ្នាក់រៀន

ស្រាប់តែឈ្មោះជា ចំរើន , សយ សុភា និង រិទ្ធិ ស្ទុះទៅវាយឈ្មោះថុង ផានិត ខ្ញុំមិនបានវាយគេទេ ខ្ញុំសូមដោះលែងខ្ញុំទៅជួបក្រុមគ្រួសារវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកែ ចំរើន ជាមេធាវីការពារអោយជនជាប់ចោទឈ្មោះ កែវ ហុងលីម នៅពេលជំនុំជំរះថា : ទាក់ទងនឹងអង្គហេតុក្នុងរឿងនេះកូនក្តីខ្ញុំគ្រាន់តែបានឈរនៅជិតគេទេ មិនបានចូលខ្លួនទៅវាយយករបស់គេទេ ក្រោយពេលដែលគេវាយយករបស់ទ្រព្យទៅអស់ ក៏កូនក្តីខ្ញុំនៅទីនោះដែរ មិនរត់ទៅណាទេ ដូច្នេះការចោទកូនក្តីខ្ញុំពីបទប្លន់ក៏មិនត្រឹមត្រូវដែរ ហើយបើថាទទួលផលចោរកម្មក៏អត់មានដែរ ព្រោះមិនបានយករបស់គេ មិនបានចាយលុយដែលលក់របស់នោះ ។ ដូច្នេះរឿងនេះជារឿងភ័ន្តច្រឡំ ខ្ញុំបាទសូមតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា :

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់បណ្តឹងសាទុក្ខ និងសារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា នៃសាលាឧទ្ធរណ៍ ចម្លើយរបស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៣ របស់ អគ្គព្រះរាជ-អាជ្ញាសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចកែប្រែបទចោទផ្តន្ទាទោសក្រោមអប្បរិមានៃទោស និង ព្យួរទោសឈ្មោះកែវ ហុងលីម នោះ ពុំទាន់មានមូលដ្ឋានច្បាស់លាស់នៅឡើយ និង ជាការបំពានទៅនឹងមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទលើកឡើងថា កូនក្តីលោកពុំបានចូលរួមក្នុងអំពើប្លន់នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា ជនជាប់ចោទពុំបានប្តឹងសាទុក្ខពីការសំរេចរបស់សាលាឧទ្ធរណ៍នោះទេ បានន័យថាជនជាប់ចោទទទួលស្គាល់នូវអំពើដែលខ្លួនបានប្រព្រឹត្តរួចហើយ ។

-យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមពុំបានចាត់ការលើជនជាប់ចោទបីនាក់ទៀតនោះ ជាការធ្វើអោយជនល្មើសរួចផុតពីទណ្ឌកម្ម ពីព្រោះថា មានភស្តុតាងច្បាស់លាស់បញ្ជាក់ពីសាវតាជាតិរបស់ជនឈ្មោះជា ចំរើន , ឈ្មោះសយ សុភា ជាសិស្សថ្នាក់ទី៧A ប្រាកដមែន ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៤៦"ជ" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទ

១-ទទួលបណ្ដឹងសាទុក្ខលេខ១១០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៣ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៤៦"ជ" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៣៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៥ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៥ ។